អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**OFFICE OF THE CO-INVESTIGATING JUDGES**
**BUREAU DES CO-JUGES D'INSTRUCTION**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 31 / 01 / 2014
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

ភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៤

**គោរពជូន**

**ឯកឧត្តម ហោ ណាំហុង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**កម្មវត្ថុ:** សំណើសុំបញ្ជូនបន្តដីកាចាត់ឲ្យស៊ើបសួរជំនួសអន្តរជាតិ ជូនទៅឯកឧត្តម Ngo Anh Dzung ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

ខ្ញុំ Mark B. Harmon សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមគោរព និងសម្ដែងការគួរសមចំពោះឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងស្នើសុំជំនួយពីឯកឧត្តម ដើម្បីយើងខ្ញុំអាចអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសអន្តរជាតិដូចបានភ្ជាប់ជូនមកជាមួយ។

បច្ចុប្បន្ននេះ ការស៊ើបអង្កេតលើសំណុំរឿង ០០៤ កំពុងដំណើរការ។ ដីកាចាត់ឲ្យស៊ើបសួរជំនួសអន្តរជាតិដូចបានភ្ជាប់ជូនមកជាមួយនេះ ស្នើសុំជំនួយផ្នែកតុលាការពីអាជ្ញាធរនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ជួយអនុញ្ញាតឲ្យអនុវត្តការស៊ើបអង្កេតក្នុងប្រទេសវៀតណាម ក្នុងគោលបំណងប្រមូលភស្តុតាង ។

00972883

D18/1

ក្នុងគោលបំណងខាងលើនេះ ការិយាល័យសហចៅក្រមស៊ើបអង្កេត ស្នើសូមឯកឧត្តម ឧបនាយករដ្ឋមន្ត្រី មេត្តាជួយសម្របសម្រួលជាមួយស្ថានទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំនៅកម្ពុជា ដើម្បីធានាឲ្យមានការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសអន្តរជាតិដូចបានភ្ជាប់ជូនមកជាមួយនេះ ដោយអនុគ្រោះ។

សូម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**Mark B. Harmon**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
International Co-Investigating Judge
Co-juge d'instruction International